ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខៈ ៤ក ១៦/២០២៥ កបទ.សអ

# សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជូនលិខិតតវ៉ាជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជាជាថ្មីម្តងទៀត ជុំវិញសកម្មភាពពង្រីកតំបន់ជម្លោះដោយកងកម្លាំងយោធាថៃ នៅតំបន់ព្រំដែនគោកកម្ពុជា-ថៃ ជាពិសេសតំបន់ដែលប្រជាពលរដ្ឋខ្មែរបាន និងកំពុងរស់នៅជាច្រើនទសវត្សរ៍មកហើយ។

១. ការវាយបន្លាលួស សំណាញ់ របាំង និងកង់ឡានដោយយោធាថៃ កាលពីខែសីហា ឆ្នាំ២០២៥ នៅចំណុចភូមិចំនួនពីរ ក្នុងឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បានបង្កនូវទុក្ខលំបាកយ៉ាងធ្ងន់ធ្ងរដល់ប្រជាជនខ្មែរជាច្រើនគ្រួសារ ដែលត្រូវបានបណ្តេញចេញពីផ្ទះសម្បែង និងដីស្រែចម្ការរបស់ពួកគេ និងកំពុងទន្ទឹងរង់ចាំដំណោះស្រាយស្ថានភាពនេះ។

២. នៅថ្ងៃទី ២៦ និង ២៨ ខែសីហា ឆ្នាំ ២០២៥ ឧត្តមសេនីយ៍ទោ Wanchana Sawasdee ប្រធានការិយាល័យសម្របសម្រួលបេសកកម្មសន្តិសុខជាតិ ក្រោមការដឹកនាំ ប្រតិបត្តិការយោធានៃកងទ័ពភូមិន្ទថៃ បានប្រកាសជាសាធារណៈនូវឱសានវាទឱ្យកម្ពុជា "ជម្លៀស" ពលរដ្ឋរបស់ខ្លួនចេញពីភូមិជោគជ័យ ក្នុងរយៈពេល ៣-៦ខែខាងមុខ បើពុំដូច្នោះទេនឹងត្រូវប្រឈមមុខពីការបណ្តេញចេញដោយការប្រើប្រាស់កម្លាំងពីសំណាក់យោធាថៃ។ ស្របពេលដែលអាជ្ញាធរថៃបានដំឡើងផ្ទាំងបដាផ្សព្វផ្សាយប្រកាសខាងលើ អភិបាលខេត្តស្រះកែវនៃព្រះរាជាណាចក្រថៃក៏បានផ្ញើលិខិតផ្លូវការមួយច្បាប់ទៅកាន់អភិបាលខេត្តបន្ទាយមានជ័យ នៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធបញ្ហានេះផងដែរ។

៣. រាល់សកម្មភាពខាងលើ និងផែនការដែលបានប្រកាសក្នុងការចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនពលរដ្ឋថៃលើតំបន់ដែលពលរដ្ឋខ្មែររាប់រយគ្រួសារបាននិងកំពុងរស់នៅរាប់ទស្សវត្សរ៍មកនោះ បង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង ស្របនឹងការប៉ុនប៉ងបោះបង្គោលព្រំដែនជាឯកតោភាគី តាមរយៈការប្រើប្រាស់មធ្យោបាយយោធា។ នេះគឺជាការរំលោភលើអាណត្តិការងាររបស់គណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) និងផ្ទុយពីស្មារតីនៃអនុស្សារណៈយោគយោលឆ្នាំ២០០០

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

(MOU-2000) ស្តីពីការវាស់វែង និងខណ្ឌសីមាព្រំដែនគោកវាងកម្ពុជា-ថៃ កិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ និងកំណត់ហេតុនៃកិច្ចប្រជុំវិសាមញ្ញនៃគណៈកម្មាធិការព្រំដែនទូទៅ (GBC) នៅថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២៥ និងលទ្ធផលកិច្ចប្រជុំវិសាមញ្ញនៃគណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគ (RBC) នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៥។

រាជរដ្ឋាភិបាលកម្ពុជា នៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការស្វែងរកដំណោះស្រាយប្រកបដោយស្មារតីមិត្តភាព ចំពោះវិវាទព្រំដែនជាមួយប្រទេសជិតខាងទាំងអស់ តាមរយៈមធ្យោបាយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ និងបន្តការរក្សាការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ ប្រកាន់នូវជំហរជាគោលការណ៍របស់ខ្លួនថា ព្រំដែនមិនត្រូវបានផ្លាស់ប្តូរដោយការប្រើប្រាស់កម្លាំងបង្ខំនោះទេ។

រាជរដ្ឋាភិបាលកម្ពុជា ជំរុញឱ្យភាគីថៃរក្សាស្ថានភាពដូចដើម និងចូលរួមដោះស្រាយជម្លោះព្រំដែនខាងលើ តាមរយៈយន្តការ GBC និង JBC ដូចដែលភាគីទាំងពីរឯកភាពគ្នា៕

ថ្ងៃពុធ ១១កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៥

N°. SM 16/2025 MFA.IC

*Unofficial Translation*

# Statement of the Ministry of Foreign Affairs and International Cooperation of The Kingdom of Cambodia

The Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia communicated another formal protest of the Royal Government of Cambodia over the acts of expanding conflict area by Thai forces in the border regions between Cambodia and Thailand, especially the areas where Cambodian communities have been living for decades.

1. First, the barbed wire, nets, barriers, and tires laid by Thai Military, in August 2025, at two villages in O Bei Chorn Commune, O Chrov District, Banteay Meanchey Province, have already caused immense hardship to many Cambodian families, who have been evicted from their homes and farmland, and are now awaiting redress of their plight.

2. Second, on 26 and 28 August 2025, Major General Wanchana Sawasdee, Director of the Mission Coordination Office for National Security under the Directorate of Operations of the Royal Thai Armed Forces, publicly declared an ultimatum for Cambodia to "evacuate" its citizens from Chouk Chey Village, in 3-6 months, or they would face forced removal by Thai military. While Thai authorities have installed announcement board to this effect, the Governor of Sa Kaeo Province of Thailand also sent a formal letter to the Governor of Banteay Meanchey Province of Cambodia, in this regard.

3. Third, the above actions and the announced plan to issue land titles to Thai citizens over the areas where hundreds of Cambodian families have lived for decades are deeply concerning and amounts to an attempt to unilaterally demarcate the border through the use of military means. This is a violation of the mandate of the Joint Commission on Demarcation for Land Boundary ( JBC ) and contrary to the spirit of the 2000 MOU on the Survey and Demarcation of Land Boundary between Cambodia and Thailand, the agreement on the ceasefire of 28 July 2025, the Agreed Minutes of the Extraordinary Meetings of the General Border Committee ( GBC ) on 7 August 2025 and the Regional Border Committee on 22 August 2025.

The Royal Government of Cambodia remains firmly committed to seeking amicable resolution to boundary disputes with all its neighbours through peaceful means in accordance to international law while remaining resolute in upholding its principled position that borders must not be changed by force.

The Royal Government of Cambodia urges the Thai side to maintain the status quo ante and to settle the above-mentioned border situation through the GBC and JBC as has been committed and mutually agreed by both sides.

Phnom Penh, 03 September 2025